| **ផែនការអនុវត្តរយៈពេលខ្លី** | | | |
|---|---|---|---|
| | **២០០៤** | **២០០៥** | **២០០៦** |
| **ទិសដៅយុទ្ធសាស្ត្រទី ៣ ផ្តល់លទ្ធភាពឱ្យទទួលបានព័ត៌មានច្បាប់ និងតុលាការឱ្យកាន់តែប្រសើរឡើង** | | | |
| ៣.១.៣ ការធ្វើឱ្យមានការបោះពុម្ពផ្សាយជាទៀងទាត់ និងជាលក្ខណៈស្ថាប័ននូវរាជកិច្ច និងទិន្នន័យព័ត៌មានច្បាប់ | →→→→→→→→→→→ X | | |
| ៣.២.២ ការប្រមូលនិងការបោះពុម្ពសេចក្តីសម្រេចរបស់តុលាការកំពូល និងសេចក្តីសម្រេចជាស្ថាពរនៃតុលាការផ្សេងទៀត | →→→→→→→→→→→ X | | |

## ទិសដៅយុទ្ធសាស្ត្រទី ៣

**អាទិភាពកំណត់៖**

៣.១.៣ ការធ្វើឱ្យមានការបោះពុម្ពផ្សាយជាទៀងទាត់ និងជាលក្ខណៈស្ថាប័ននូវរាជកិច្ច និងទិន្នន័យព័ត៌មានច្បាប់

៣.២.២ ការប្រមូល និងការបោះពុម្ពសេចក្តីសម្រេចរបស់តុលាការកំពូល និងសេចក្តីសម្រេចជាស្ថាពរនៃតុលាការផ្សេងទៀត

| **ទិសដៅយុទ្ធសាស្ត្រ៖** ផ្តល់លទ្ធភាពឱ្យទទួលបានព័ត៌មានអំពីច្បាប់ និងតុលាការ ឱ្យកាន់តែប្រសើរឡើង | | **លទ្ធផលរំពឹងទុក៖** ការយល់ដឹងជាសាធារណៈត្រូវបានលើកកម្ពស់ ហើយចំណេះដឹង និងលទ្ធភាពទទួលបានព័ត៌មានច្បាប់ និងយុត្តិធម៌កាន់តែប្រសើរ | | | |
|---|---|---|---|---|---|
| **សកម្មភាពជាអាទិភាព** | **ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ** | **ស្ថាប័នដទៃទៀតដែលកំពុងមានការពាក់ព័ន្ធ** | **រយៈពេល** | **សកម្មភាពដែលត្រូវធ្វើ** | **សេចក្តីសង្កេតបន្ថែម** |
| ៣.១ បោះពុម្ពច្បាប់ទាំងឡាយដែលមាន និងនីតិកម្មពាក់ព័ន្ធទាំងអស់រួមទាំងសេចក្តីណែនាំ និងទម្លាប់អនុវត្តជាភាសាខ្មែរ បោះពុម្ពច្បាប់ថ្មី និងនីតិកម្មពាក់ព័ន្ធទាំងអស់ជាផ្លូវការឱ្យទាន់ពេលវេលា និងសព្វគ្រប់ ឧទាហរណ៍ រាជកិច្ច សម្រាប់សេចក្តីត្រូវការនៃចៅក្រម មេធាវី និស្សិតច្បាប់ មន្ត្រីរដ្ឋាភិបាល វិស័យឯកជន សង្គមស៊ីវិល និងភាគីមានផលប្រយោជន៍ដទៃទៀត | | | | | |

| | | | | | |
|---|---|---|---|---|---|
| ៣.១.៣ ការធ្វើឱ្យមានការបោះពុម្ពផ្សាយជាទៀងទាត់ និង ជាលក្ខណៈស្ថាប័ននូវរាជកិច្ច និងទិន្នន័យព័ត៌មានច្បាប់ | ទី.ឥ.មន្ត្រី<br>អគ្គនាយកដ្ឋានរាជកិច្ច<br>ក.ក.ច.ន.យ<br>ក្រសួងនានា និង<br>ស្ថាប័នរដ្ឋាភិបាល | UNDP | ២00៤-២00៥ | ធ្វើការសិក្សារិះរកធ្វើឱ្យការផ្សព្វផ្សាយបច្ចុប្បន្ន បានប្រសើរឡើង និងក្បៀងគររកជំនួយសម្រាប់អនុវត្តអនុសាសន៍បានមកពីការសិក្សា ( ការប្រមូលព័ត៌មានខ្លឹមសារ ការគ្រប់គ្រង ការត្រួតពិនិត្យយន្តការ ចែកចាយ មូលនិធិ បរិក្ខារចាំបាច់ ផែនការកម្ម ចីរភាព) | UNDP សិក្សាស្រាវជ្រាវនេះរួចហើយចំនួន ៣ សប្តាហ៍កាលពី ថ្ងៃទី២៨/0៦-១៦/0៧/២00៣។ រាជរដ្ឋា-ភិបាលបានតម្លើងនាយកដ្ឋានរាជកិច្ចឱ្យទៅជាអគ្គនាយក-ដ្ឋាន និងបំពាក់បន្ថែមនូវធន-ធានមនុស្ស និងសម្ភារៈ។ |
| ៣.២ បោះពុម្ពសាលក្រមដែលមាន និងផលិតព្រឹត្តិបត្រសង្ខេបរឿងក្តី សម្រាប់បោះពុម្ព និងផ្សព្វផ្សាយសាលក្រម សេចក្តីសម្រេច និងវិធានផ្សេងៗរបស់តុលាការ និងធានាឱ្យសាលក្រមតុលាការ អាចរកបាននៅពេលមានការស្នើសុំ | | | | | |
| ៣.២.២ ការប្រមូល និងការបោះពុម្ពសេចក្តីសម្រេចរបស់តុលាការតុលាការកំពូល និងសេចក្តីសម្រេចជាស្ថាពរនៃតុលាការផ្សេងទៀត | តុលាការកំពូល<br>ឧត្តម.ចៅក្រម<br>ក្រ.យុត្តិធម៌<br>សាលាជំរះក្តី<br>សា.ចៅក្រម<br>មជ្ឈមណ្ឌល.មេធាវី | ប្រទេសបារាំង<br>UNDP | ២00៤-២00៥ | ១-រចនាវិធីសាស្ត្រឯកភាពគ្នាមួយ ដើម្បីប្រមូល និងបោះពុម្ពសាលក្រមតុលាការ-កំពូលនិងសាលក្រមស្ថាពរនៃតុលាការផ្សេងទៀត និងធ្វើការផ្សព្វផ្សាយជាសាធារណៈ<br>២- បញ្ចូលមុខវិជ្ជាសរសេរសេចក្តីសម្រេចរបស់តុលាការទៅក្នុងកម្មវិធី | មុខវិជ្ជាអំពីការសរសេរសេចក្តីសម្រេចត្រូវបានបញ្ចូលទៅក្នុងកម្មវិធីសិក្សានៃសាលា-ភូមិន្ទចៅក្រមរួចហើយ ការផ្សព្វផ្សាយនូវសេចក្តីសម្រេចគួរចាប់ផ្តើមពីតុលាការកំពូល និងសាលាឧទ្ធរណ៍ និងតុលាការ |

| | | | | | |
|---|---|---|---|---|---|
| | | | | សិក្សាសាលាភូមិន្ទចៅក្រម<br>៣-បង្កើតយន្តការតាមដាននៅក្នុងឧត្តម-ក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីពិនិត្យការអនុវត្ត និងជួយឱ្យការសរសេរសេចក្ដីសម្រេចបានប្រសើរ<br>៤-រៀបចំកម្មវិធីបណ្ដុះបណ្ដាលបន្តសម្រាប់ចៅក្រមក្នុងតំណែង | ខេត្ត-ក្រុង ដែលមានរឿងក្ដីច្រើន ហើយជាបន្តបន្ទាប់ទៅតុលាការទាំងអស់តែម្ដង។ UNDP បានសន្យាជួយតុលា-ការកំពូលនេះរួចហើយ មុខវិជ្ជាអំពីការវិភាគសេចក្ដី-សម្រេចរបស់តុលាការ គួរតែបញ្ចូលទៅក្នុងកម្មវិធីសិក្សានៅតាមមហាវិទ្យាល័យច្បាប់នានា ។ |